ទំព័រពិត

# ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ព្រមទាំង ទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ

## តើអ្វីជាសិទ្ធិមនុស្ស?

សិទ្ធិមនុស្ស គឺជាសិទ្ធិដែលមានជាប់មកជាមួយគ្រប់មនុស្សទាំងអស់។ យើងគ្រប់គ្នា គឺមានសិទ្ធិស្មើគ្នាក្នុងការទទួលបាននូវសិទ្ធិមនុស្ស ដោយគ្មានការរើសអើង មិនថា យើងមានសញ្ជាតិ លំនៅឋាន ភេទ ដើមកំណើតជាតិ ឬ សង្គម ពណ៌សម្បុរ សាសនា ភាសា ឬ កត្តាផ្សេងៗ ដូចជា អាយុ ពិការភាព ស្ថានភាពសុខភាព ទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ។ សិទ្ធិទាំងនេះ មិនថាជាសិទ្ធ ពលរដ្ឋ និង សិទ្ធិនយោបាយ ទេ (សិទ្ធិរស់រាន មានជីវិត សមភាពចំពោះមុខច្បាប់ និង សេរីភាពក្នុងការបញ្ចេញមតិ) ឬ សិទ្ធិ សេដ្ឋកិច្ច សង្គម កិច្ច និង វប្បធម៌ (សិទ្ធិ ក្នុងការទទួលបានការងារ សន្តិសុខ សង្គម និង ការអប់រំ) គឺជាសិទ្ធិដែលមាន អាចបែងចែកជាសិទ្ធិសកល ដែលប្រទាក់ក្រឡាគ្នា និង ពឹងពាក់គ្នា។

សិទ្ធិមនុស្សត្រូវបានគេបង្កើតឡើង និង បង្ហាញយ៉ាងច្បាស់នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨) ជាការឆ្លើយតបនឹងភាពសាហាវយង់ឃ្នងរបស់សង្គ្រាមលោកលើកទី ២។ សិទ្ធិមនុស្សជាសកលតែងតែត្រូវបាន គេសម្តែងចេញ និង ធានាដោយច្បាប់ក្នុងទម្រង់ជាសន្ធិសញ្ញា ច្បាប់អន្តរជាតិប្រពៃណី គោលការណ៍ទូទៅ និង ប្រភពផ្សេងទៀតរបស់ច្បាប់អន្តរជាតិ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិបានដាក់ជាកាតព្វកិច្ចដល់រដ្ឋអោយប្រព្រឹត្ត ដោយវិធីណាមួយជាក់លាក់ និង ជៀសវាងអំពើណាមួយជាក់លាក់ ដើម្បីជាការលើកកម្ពស់ និង ការពារសិទ្ធិមនុស្ស និង សិទ្ធជាមូលដ្ឋានរបស់បុគ្គល ឬ ក្រុមណាមួយ។

ដោយក្លាយជាភាគីនៃសន្ធិសញ្ញាអន្តរជាតិ រដ្ឋមានកាតព្វកិច្ច និង តួនាទីក្រោមច្បាប់អន្តរជាតិ ដោយគោរព ការពារ និង បំពេញនូវសិទ្ធមនុស្ស។ កាតព្វកិច្ចក្នុងការគោរពមានន័យថា រដ្ឋមិនត្រូវជ្រៀតជ្រែក ជាមួយនឹង ឬ មិនត្រូវបន្ថយនូវការទទួលបាននូវសិទ្ធិមនុស្សទេ។ កាតព្វកិច្ចក្នុងការការពារគឺតម្រូវអោយរដ្ឋការពារបុគ្គលឬក្រុមមនុស្ស ពីការរំលោភបំពាននូវសិទ្ធិមនុស្សពីសំណាក់ភាគីទីបីឡើយ។ កាតព្វកិច្ច ក្នុងការបំពេញមានន័យថារដ្ឋ ត្រូវមានសកម្មភាពជាវិជ្ជមានក្នុងការសម្រួលដល់ការទទួលបាននូវសិទ្ធិមនុស្សជាមូលដ្ឋាន។

## តើអ្វីជាច្បាប់សិទ្ធិមនុស្សអន្តរជាតិ?

សិទ្ធិមនុស្សអន្តរជាតិបានដាក់នូវកាតព្វកិច្ចដែលរដ្ឋត្រូវតែគោរព។ តាមរយៈការផ្តល់សច្ចាប័ននៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ រដ្ឋសន្យាដាក់ក្នុងវិធានការ និង ច្បាប់ក្នុងស្រុក នូវកាតព្វកិច្ច និង តួនាទីក្នុងសន្ធិសញ្ញារបស់ពួកគេ។ នៅពេលដែលដំណើរច្បាប់ក្នុងស្រុក បរាជ័យក្នុងការដោះស្រាយ ការរំលោភសិទ្ធិមនុស្ស យន្តការ និង និតីវិធីសម្រាប់តវ៉ា របស់បុគ្គល ឬ បណ្តឹងមាននៅឯថ្នាក់តំបន់ និង អន្តរជាតិ ដើម្បីធានាថាស្តង់ដារនៃសិទ្ធិមនុស្សអន្តរជាតិ ត្រូវបានគេគោរព ប្រតិបត្តិ និង រឹតបន្តឹងនៅក្នុងស្រុក។ នៅថ្នាក់អន្តរជាតិ យន្តការទាំងនេះរួមមាន គណៈកម្មការសន្ធិសញ្ញា គណៈកម្មាធិកាជំនាញ បង្កើតដោយសន្ធិសញ្ញា និង មានតួនាទីក្នុងការឃ្លាំមើល ការប្រតិបត្តិលើកាតព្វកច្ចដូចមានចែងក្នុងសន្ធិសញ្ញា និង អ្នករាយការណ៍ពិសេស និង អ្នកជំនាញឯករាជ្យផ្សេងទៀតតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដើម្បីស៊ើបអង្កេត និង រាយការណ៍ពីការប្រឈមមុខរបស់សិទ្ធិមនុស្ស។

## តើវាស្របច្បាប់ដែរឬទេ ក្នុងការរើសអើងមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ មនុស្សប្តូរភេទ ឬ មនុស្សភេទពីរ?

ទេ។ សិទ្ធិក្នុងការទទួលបានសមភាព និង ភាពមិនរើសអើង គឺជាគោលការណ៍ស្នូល នៃសិទ្ធិមនុស្ស ដែលមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង សន្ធិសញ្ញាសិទ្ធមនុស្ស។ ពាក្យផ្តើម នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺចែងយ៉ាងច្បាស់ថា " *គ្រប់មនុស្សទាំងអស់ កើតមកមានសេរីភាព និង ស្មើភាព ដោយទទួលបានភាពថ្លៃថ្នូរ និង សិទ្ធិ*"។

ការធានាពីសមភាព និង ភាពមិនរើសអើងផ្តល់ដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិអនុវត្តចំពោះមនុស្សទាំងអស់ មិនថាមានភេទ ទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ឬ "ស្ថានភាពដទៃទៀត" ។ វាគ្មានរូបភាពណាមួយជាក់លាក់ ឬ ខលើកលែងលាក់កំបាំងណាមួយ នៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សរបស់យើង ដែលអនុញ្ញាតអោយរដ្ឋធានានូវសិទ្ធិពេញលេញរបស់មនុស្សមួយចំនួន ហើយ ដកហូតសិទ្ធិពីអ្នកដទៃ ដោយយោងលើមូលដ្ឋាននៃទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ។

ម៉្យាងវិញទៀត គណៈកម្មាធិការការសន្ធិសញ្ញាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានបញ្ជាក់ថាទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ត្រូវបានគេរាប់បញ្ចូល ក្នុងចំណោមករណីរើសអើងក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ នេះមានន័យថា វាជាការខុសច្បាប់ក្នុងការបង្កើតភាពខុសគ្នានៃសិទ្ធិមនុស្ស ដោយផ្អែកលើការពិតដែលថា មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬ មនុស្សប្តូរភេទ (LGBT) ក៏ដូចជាការខុសច្បាប់ក្នុងការរើសអើងទៅលើពណ៌សម្បុរ ជាតិសាសន៍ ភេទ សាសនា ឬស្ថានភាពដទៃទៀត។ ជំហរនេះ ត្រូវបានគេបញ្ជាក់ម្តងហើយម្តងទៀត ក្នុងសេចក្តីសម្រេចចិត្ត និង ការណែនាំទូទៅ ដែលត្រូវបានបង្កើតដោយគណៈកម្មាធិការសន្ធិសញ្ញាដូចជា គណៈកម្មាធិការអង្គការសហប្រជាជាតិសិទ្ធិមនុស្ស គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ គណៈកម្មាធិការសិទ្ធិកុមារ គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម និង គណៈកម្មាធិការលុបបំបាត់ការរើសអើងលើស្ត្រី។

## តើអ្វីជាទម្រង់ទូទៅនៃការរំលោភសិទ្ធិមនុស្សដ៏ញឹកញាប់បំផុតទៅលើមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ?

ការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិសិទ្ធិមនុស្ស បានចងក្រងជាឯកសារយ៉ាងទូលំទូលាយអំពីការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តឡើង ទៅលើបុគ្គលដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ។

ការរំលោភទាំងនេះ រួមមាន:

» ការវាយប្រហារជាហិង្សា ចាប់ពីការរំលោភដោយការប្រើប្រាស់ពាក្យសម្តីយ៉ាងកម្រោល និង ការគំរាមកំហែងផ្លូវចិត្ត រហូតដល់ការវាយប្រហារលើ រាងកាយ ការវាយតប់ ទារុណកម្ម ការចាប់ជំរិត និង ការសម្លាប់ជាគោល ដៅ។

» ច្បាប់ព្រហ្មទណ្ឌដែលមានការរើសអើង តែងតែត្រូវបានគេប្រើដើម្បីបៀតបៀន និង ធ្វើបាបលើមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬ មនុស្សប្តូរភេទ (LGBT) រួមមានច្បាប់ដែលចាត់ទុកជាបទល្មើស ព្រហ្មទណ្ឌចំពោះទំនាក់ទំនងភេទដូចគ្នាជាឯកជន ដែលជាការបំពាន លើសិទ្ធិបុគ្គល និង សេរីភាពពីការរើសអើង។

» ការរើសអើងដាក់កំហិតលើសេរីភាពក្នុងការបញ្ចេញមតិ និង មានការរិតត្បិតទៅលើការអនុវត្តសិទ្ធិសេរីភាពក្នុងការចូលជាសមាគម និង ជួបជុំ រួមមានច្បាប់ដែលហាមឃាត់ការផ្សព្វផ្សាយព័ត៌មានពីសកម្មភាព រួមភេទដូចគ្នា ក្រោមរូបភាពរឹតត្បិតការផ្សព្វផ្សាយនៃ ″ការឃោសនា″អំពីមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬ មនុស្សប្តូរភេទ (LGBT) ។

» ការប្រព្រឹត្តតាមការរើសអើង ដែលអាចកើតឡើងក្នុងគ្រប់រូភាពប្រចាំថ្ងៃ រួមមាន កន្លែងធ្វើការ សាលារៀន គេហដ្ឋាន និង មន្ទីរពេទ្យ។ ដោយគ្មានការហាមឃាត់ ការរើសអើងក្នុងច្បាប់ជាតិពីភាគីទីបី ទៅលើទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ធ្វើអោយការប្រព្រឹត្តដោយរើសអើងនៅតែបន្តកើតឡើង ដោយគ្មានការត្រួតពិនិត្យ ដោយបន្សល់នូវការជួយអន្តរាគមន៍តិចតួចចំពោះមនុស្សដែលរងការប៉ះពាល់។ នៅក្នុងបរិបទនេះ កង្វះខាតនៃការទទួលស្គាល់នៃទំនាក់ទំនងភេទដូចគ្នា ឬ អត្តសញ្ញាណរបស់មនុស្សអាចធ្វើអោយមានផលប៉ះពាល់ដោយរើងអើងទៅលើ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬ មនុស្សប្តូរភេទ (LGBT) ជាច្រើន។

## តើមហាសន្និបាត និង ក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការសហប្រជាជាតិបាននិយាយដូចម្តេចខ្លះចំពោះប្រធានបទនេះ?

នៅក្នុងសេចក្តីសម្រេចមួយចំនួន មហាសន្និបាតអង្គការសហប្រជាជាតិបានអំពាវនាវឲ្យរដ្ឋទាំងឡាយ ធានាការការពារសិទ្ធិរស់រានមានជីវិតដល់មនុស្សទាំងអស់ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន និង ដើម្បីស៊ើបអង្កេតជាបន្ទាន់ នឹងហ្មត់ចត់ ចំពោះការសម្លាប់ទាំងអស់រួមទាំងការសម្លាប់ដែលកើតឡើងដោយទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័ររបស់ជនរងគ្រោះ។ (សូមមើលឧទាហរណ៍ សេចក្តីសម្រេច A/RES/67/168)។

នៅខែមិថុនា ឆ្នាំ ២០១១ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានក្លាយជាស្ថាប័នអន្តរដ្ឋាភិបាលលើទីមួយរបស់អង្គការសហប្រជាជាតិដែលបានអនុម័តសេចក្តីសម្រេចពហុគោលបំណងស្តីពីសិទ្ធិមនុស្សទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ។ សេចក្តីសម្រេច១៧ /១៩ សម្តែង“ការព្រួយបារម្ភយ៉ាងខ្លាំង ” ចំពោះអំពើហិង្សា និង ការរើសអើងទៅលើបុគ្គលដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ព្រមទាំងបានស្នើឲ្យធ្វើការសិក្សាពីវិសាលភាព និង កម្រិតនៃការរំលោភទាំងនេះ ព្រមទាំងវិធានការដែលចាំបាច់ដោះស្រាយ។

ការសិក្សាដែលបានស្នើសុំនោះ ដែលបានធ្វើឡើងដោយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ត្រូវបានផ្សព្វផ្សាយនៅខែធ្នូ ឆ្នាំ ២០១១។ វាបានចង្អុលបង្ហាញទៅអំពើហិង្សា និង ការរើសអើងទៅលើបុគ្គលដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ។ ការរកឃើញ និង អនុសាសន៍របស់ការិយាល័យនេះបង្កើតបានជាមូលដ្ឋាននៃការពិភាក្សាជាក្រុមដែលបានធ្វើឡើងនៅក្រុមប្រឹក្សានៅខែមីនា ឆ្នាំ ២០១២ ដែលជាលើកដំបូងដែលការពិភាក្សាអន្តរភិបាលជាផ្លូវការស្តីពីប្រធានបទនេះដែលបានកើតឡើងនៅអង្គការសហប្រជាជាតិ។

## តើជំហានជាក់ស្តែងដែលច្បាប់អន្តរជាតិតម្រូវឲ្យរដ្ឋទាំងឡាយធ្វើដើម្បីការពារសិទ្ធិរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬ មនុស្សប្តូរភេទ?

កាតព្វកិច្ចតាមផ្លូវច្បាប់ស្នូលរបស់រដ្ឋទាក់ទងនឹងកិច្ចការពារសិទ្ធិមនុស្សរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬ មនុស្សប្តូរភេទ រួមទាំងកាតព្វកិច្ចៈ

» *ការពារ* បុគ្គលកុំឲ្យមានអំពើហិង្សា ដោយសារការស្អប់ការស្រលាញ់ភេទដូចគ្នា និង ការប្តូរភេទ និង បង្កាការទារុណកម្ម និង ការប្រព្រឹត្តសាហាវ អមនុស្សធម៌ និង បន្ទាបបន្ថោក។ អនុម័តច្បាប់ ស្តីពីឧក្រិដ្ឋកម្មរើសអើង ដែលមិនលើកទឹក ចិត្ត ឲ្យមានអំពើហិង្សា ទៅលើបុគ្គលដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ហើយ បង្កើតប្រព័ន្ធដែលមានប្រសិទ្ធភាពសម្រាប់រាយ ការណ៍អំពីការរើងអើងដែលជំរុញដោយអំពើហិង្សា រួមទាំងស៊ើបអង្កេត និង ចោទប្រកាន់ជន ល្មើស និង នាំអ្នកទទួលខុសត្រូវមកកាត់ទោស។ ធ្វើការ បណ្តុះបណ្តាលដល់ មន្ត្រីអនុវត្តច្បាប់ និង ត្រួតពិនិត្យកន្លែងឃុំខ្លួន និង ផ្តល់ នូវប្រព័ន្ធឲ្យជនរងគ្រោះ ស្វែងរកដំណោះស្រាយ។ បន្ថែមពីនេះ ច្បាប់ និង គោលនយោបាយស្តីពីជ្រកកោនគួរតែទទួលស្គាល់ថា ការចោទប្រកាន់ ដោយសារទំនោរផ្លូវភេទ អាចជាមូលដ្ឋានប្រសិទ្ធភាពសម្រាប់ការស្នើសុំ ជ្រោកកោន។

» *លុប* ច្បាប់ដែលចាត់ទុកការស្រលាញ់ភេទដូចគ្នាជាបទល្មើសព្រហ្មទណ្ឌ រួមទាំងច្បាប់ដែលចាត់ទុកការរួមភេទឯកជជនរវាងនីតិជនតាមការព្រមព្រៀង ជាបទល្មើសព្រហ្មទណ្ឌ។ ធានាថា គ្នាបុគ្គលណាត្រូវបានចាប់ខ្លួន ឬ ឃាត់ខ្លួន ដោយសារទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ ហើយមិនស្ថិតក្រោមការ ត្រួត ពិនិត្យផ្លូវកាយបន្ថោកបន្ទាប ដែលមានគោលបំណងកំណត់អត្ត សញ្ញាណយេន ឌ័រឡើយ។

» *ហាមឃាត់* ការរើសអើងដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេន ឌ័រ។ អនុម័តច្បាប់ដែលហាមឃាត់ការរើងអើងដោយមូលហេតុទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ។ ផ្តល់ការអប់រំ និង ការបណ្តុះបណ្តាល ដើម្បីទប់ ស្កាត់ការរើស អើង និង ស្លាកស្នាមទុយស៍របស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬ មនុស្សប្តូរភេទ និង មនុស្សភេទពីរ។

» *ការពារ* សេរីភាពបញ្ចេញមតិ ធ្វើសមាគម និង ការជួបជុំគ្នាដោយសន្តិវិធី ដល់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទ ដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬ មនុស្សប្តូរភេទទាំងអស់ ហើយធានាថា គ្មានការរិតត្បិតណាមួយធ្វើឡើងទៅលើទាំងនេះ សូម្បិតែការរិតត្បិតជាការស្របច្បាប់ និង មានទំហំសមហេតុសមផល និង សមាមាត្រក៏ដោយ ដែលជាការរើសអើងដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណ យេនឌ័រឡើយ។ លើកកម្ពស់វប្បធម៌ស្មើភាពគ្នា និង ភាពចម្រុះ គ្នាដែល មានការគោរពសិទ្ធិរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុស ស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬ មនុស្សប្តូរភេទ។